00616250

A410/2/1

**នៅចំពោះមុខ អង្គបុរេជំនុំជម្រះ**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.បជ ១៤៧)

ភាគីដាក់ឯកសារ: សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី

ដាក់ជូន: អង្គបុរេជំនុំជម្រះ

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី១២ ខែតុលា ឆ្នាំ២០១០

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ ~~អសមចស~~ អ.បជ សម្ងាត់ / Confidential / Confidentiel

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន: សាធារណៈ / Public

ឈ្មោះមន្ត្រីកត់ត្រា: Peang Tola 21/07/2011

ហត្ថលេខា:

**បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងចម្លើយរបស់សហចៅក្រមស៊ើបអង្កេតទៅនឹងសំណើ**

**ស្តីពីការរក្សាការសម្ងាត់ សមភាព និងយុត្តិធម៌**

<u>ដាក់ដោយ</u>៖

**សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ហុង គីមសួន

លោកស្រី ស៊ិន សុវ៉ន

លោក គង់ ពិសី

លោក យុង ផានិត

លោកស្រី Lyma NGUYEN

លោកស្រី Silke STUDZINSKY

<u>ផ្ញើជូន</u>៖

<u>ផ្ញើជូន</u>៖

**អង្គបុរេជំនុំជម្រះ**

ចៅក្រម ប្រាក់ គឹមសាន

ចៅក្រម ន័យ ថុល

ចៅក្រម ហួត វុទ្ធី

ចៅក្រម Catherine MARCHI-UHEL

ចៅក្រម Rowan DOWNING

**ឯកសារដើម**
**ORIGINAL/ORIGINAL**
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 20 / 10 / 2010
ម៉ោង (Time/Heure): 15:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

00616251

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Andrew T. CAYLEY

**មេធាវីតំណាងភាគីដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ឡោ ជុនធី

លោក គីម ម៉េងឃី

លោកស្រី ម៉ុច សុវណ្ណារី

លោកស្រី ជេត វណ្ណលី

លោក ពេជ អង្គ

លោក វ៉ែន ពៅ

លោកស្រី Martine JACQUIN

លោក Phillipe CANONNE

លោកស្រី Elizabeth RABESANDRATANA

លោកស្រី Annie DELAHAIE

លោក Olivier BAHOUGNE

លោកស្រី Lyma NGUYEN

លោក Mahdev MOHAN

លោកស្រី Marie GUIRAUD

លោក Patrick BAUDOIN

លោកស្រី Fabienne TRUSSES-NAPROUS

លោក Ferdinand DJAMMEN-NZEPA

លោកស្រី Christine MARTINEAU

លោកស្រី Laure DESFORGES

លោកស្រី Isabelle DURAND

លោក Emmanuel ALTIT

លោក Emmanuel JACOMY

**សហមេធាវីការពារក្តីជនត្រូវចោទ៖**

**អៀង សារី**

លោក អាង ឧត្តម

លោក Michael G. KARNAVAS

**អៀង ធីរិទ្ធ**

លោក ផាត់ ពៅស៊ាង

លោកស្រី Diana ELLIS

**នួន ជា**

លោក សុន អរុណ

លោក Michiel PESTMAN

លោក Victor KOPPE

**ខៀវ សំផន**

លោក ស សូវាន

លោក Jacques VERGES

**កាំង ហ្គេកអ៊ាវ ហៅ ឌុច**

លោក ការ សាវុត្ថ

លោក កង ឫទ្ធារី

00616252

លោក Daniel LOSQ

លោក Julien RIVET

លោក Pascal Aubion

លោកស្រី Francoise GAUTRY

លោក Barnabe NEKUIE

លោក នី ចាន់ឌី

## I. សាវតារនីតិវិធី និងសេចក្តីផ្តើម

១. នៅថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១០ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានដាក់ "សំណើស្តីពីការរក្សាការសម្ងាត់ សមភាព និងយុត្តិធម៌"[១] ចំពោះបញ្ហាផ្សេងៗទាក់ទិននឹងលក្ខខណ្ឌធ្វើការងាររបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដែលបានកើតឡើងនៅមជ្ឈមណ្ឌលព័ត៌មានសាធារណៈ នៅក្រុងភ្នំពេញ។ ក្នុងចំណោមបញ្ហានានា សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីកត់សម្គាល់ឃើញថា មិនមានការធានាដល់ការគោរពតាមកាតព្វកិច្ចការសម្ងាត់នៃវិជ្ជាជីវៈ ទៅតាមលក្ខខណ្ឌការងារបច្ចុប្បន្នឡើយ។ នៅក្នុងបណ្តឹងឧទ្ធរណ៍នេះ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី សូមយោងទៅដល់កថាខណ្ឌ ១-២៩ នៃសំណើ។

២. នៅថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១០ ការិយាល័យសហចៅក្រមស៊ើបអង្កេត ("ក.ស.ច.ស") បានឆ្លើយតបទៅនឹងសំណើនោះ និងបានសម្រេចថា បញ្ហាកង្វល់នានាដែលកើតឡើងនោះមិនស្ថិតនៅក្រោមយុត្តាធិការរបស់ខ្លួនទេ[២]។ ស.ច.ស បានបញ្ជូនសំណើនេះទៅប្រធាន និងអនុប្រធានការិយាល័យរដ្ឋបាល ទោះបីសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីធ្លាប់បានលើកបញ្ហាកង្វល់ទាំងអស់នេះ ជម្រាបទៅប្រធានការិយាល័យរដ្ឋបាលជាច្រើនដង តែមិនបានទទួលចម្លើយតបយ៉ាងត្រឹមត្រូវក្តី។ ស.ច.ស ក៏បានទទួលព័ត៌មានពីបញ្ហានេះដែរ។

៣. នៅថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១០ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងចម្លើយតបរបស់ ស.ច.ស[៣]។ បណ្តឹងឧទ្ធរណ៍នេះមានគោលបំណងស្នើសុំឱ្យ អ.ប.ជ ប្រកាសទទួលយកបណ្តឹងឧទ្ធរណ៍នេះ និងសម្រេចលើអង្គសេចក្តីនៃសំណើ។

---

[១] សំណើរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីស្តីពីការរក្សាការសម្ងាត់ សមភាព និងយុត្តិធម៌ ថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១០ ឯកសារលេខ A410។

[២] ចម្លើយតបរបស់សហចៅក្រមស៊ើបអង្កេតទៅលើសំណើស្តីពី ការរក្សាការសម្ងាត់ សមភាព និងយុត្តិធម៌ ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១០ ឯកសារលេខ A410/1 ទំព័រ២។

[៣] លិខិតជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍ ឯកសារលេខ A410/2។

## II. ច្បាប់ និងវិធានជាធរមាន

៤. ច្បាប់ និងវិធានដែលពាក់ព័ន្ធដែលបណ្តឹងឧទ្ធរណ៍នេះបានយោង គឺវិធាន ២១ និង វិធាន ២៣ នៃវិធានផ្ទៃក្នុង ("*IR*") មាត្រា ២០ ថ្មី មាត្រា ២៣ ថ្មី និងមាត្រា ៣៣ ថ្មី នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា[៤] ("ច្បាប់ អ.វ.ត.ក") សេចក្តីណែនាំ និងគោលការណ៍មូលដ្ឋានស្តីពីសិទ្ធិទទួលបានឧបាស្រ័យ និងសំណងរបស់ជនរងគ្រោះពីការបំពានធ្ងន់ធ្ងរលើច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងការបំពានធ្ងន់ធ្ងរលើច្បាប់មនុស្សធម៌អន្តរជាតិ[៥] *("គោលការណ៍មូលដ្ឋានរបស់អ.ស.ប")* កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ[៦] ("*ICCPR*") និងក្រមសីលធម៌វិជ្ជាជីវៈមេធាវីដែលបានទទួលអាជ្ញាប័ណ្ណពីគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។

## III. ភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍

៥. បណ្តឹងឧទ្ធរណ៍នេះអាចទទួលយកបាន អនុលោមតាមវិធានផ្ទៃក្នុង២១(១)(ក) និង (ខ)។ វិធាននេះចែងថា៖

> "ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ វិធានផ្ទៃក្នុង សេចក្តីណែនាំអនុវត្ត និងបទបញ្ជារដ្ឋបាលទាំងអស់ជាធរមាន ត្រូវតែបកស្រាយក្នុងន័យ**ការពារជានិច្ច**

---

[៤] ច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ នៅគេហទំព័រ http://www.eccc.gov.kh/english/cabinet/law/4/KR_Law_as_amended_27_Oct_2004_Eng.pdf

[៥] មហាសន្និបាតអ.ស.ប, សេចក្តីណែនាំ និងគោលការណ៍មូលដ្ឋានស្តីពីសិទ្ធិទទួលបានឧបាស្រ័យនិងសំណងរបស់ជនរងគ្រោះពីការបំពានធ្ងន់ធ្ងរលើច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងការបំពានធ្ងន់ធ្ងរលើច្បាប់មនុស្សធម៌អន្តរជាតិ (Basic Principles and Guidelines on the Right to a Remedy and Reparation for Victims of Gross Violations of International Human Rights Law and Serious Violations of International Humanitarian Law)៖ សេចក្តីសម្រេច/អនុម័តដោយមហាសន្និបាត នៅថ្ងៃទី២១ ខែមីនា ឆ្នាំ២០០៦ ឯកសារលេខ A/RES/60/147 អាចរកបាននៅគេហទំព័រ http://www.ohchr.org/refworld/docid/4721cb942.html [បើកមើលនៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១០]។

[៦] កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ, សេចក្តីសម្រេចមហាសន្និបាតអង្គការសហប្រជាជាតិ លេខ 2200A[XXI] ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦។

**ដល់ប្រយោជន៍របស់ ... ជនរងគ្រោះ** ដើម្បីធានាអំពីសច្ចភាពផ្លូវច្បាប់ និងកិច្ចដំណើរការនីតិវិធីប្រកបដោយតម្លាភាព ដោយគិតដល់លក្ខណៈពិសេសរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដូចមានចែងក្នុងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ និងកិច្ចព្រមព្រៀង។ ក្នុងបរិបទនេះ៖

ក- ដំណើរការនីតិវិធីក្នុងអង្គជំនុំជម្រះវិសាមញ្ញ ត្រូវតែមានយុត្តិធម៌ និងត្រូវគោរពគោលការណ៍ចំពោះមុខ ហើយត្រូវរក្សាបាននូវតុល្យភាពរវាងសិទ្ធិរបស់ភាគីទាំងឡាយ ...

ខ- (...)

គ- **អង្គជំនុំជម្រះវិសាមញ្ញត្រូវធានាថា** ជនរងគ្រោះត្រូវទទួលបានការជូនព័ត៌មាន ហើយ**សិទ្ធិរបស់ជនរងគ្រោះត្រូវបានការពារ** ក្នុងអំឡុងពេលនៃដំណើរការនីតិវិធីរឿងក្តី"។ (គូសបញ្ជាក់បន្ថែម)

៦. នៅថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១០ អង្គបុរេជំនុំជម្រះបានសម្រេចទទួលយកបណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តី អៀង សារី អនុលោមតាមវិធាន២១។ អ.ប.ជ បានសម្រេចថា៖ "បើទោះបីជាច្បាប់ជាធរមានពុំផ្តល់សិទ្ធិឲ្យបានជាក់លាក់ដល់ជនត្រូវចោទ ក្នុងការប្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីជូនដំណឹងស្តីពីការដាក់សំណុំឯកសារពុំគ្រប់គ្រាន់ក្តី ក៏អង្គបុរេជំនុំជម្រះបានសម្រេច ... វិធាន២១ តម្រូវថា អង្គបុរេជំនុំជម្រះត្រូវបកស្រាយឲ្យបានទូលំទូលាយ នូវសិទ្ធិរបស់ជនត្រូវចោទក្នុងការប្តឹងឧទ្ធរណ៍ ដើម្បីធានាថា សិទ្ធិរបស់ជនត្រូវចោទក្នុងការទទួលបានការកាត់សេចក្តីដោយយុត្តិធម៌ ត្រូវបានគាំពារក្នុងកាលៈទេសៈនេះ"[៧]។

---

[៧] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់ ក.ស.ច.ស បដិសេធមិនទទួលយកការដាក់ឯកសារចម្លើយតបរបស់លោក អៀង សារី ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន៦៦ និងសេចក្តីសង្កេតបន្ថែម និងសំណើសុំផ្អាកដំណើរការនីតិវិធី ឯកសារលេខ D390/1/2/4 កថាខណ្ឌ១៣។

អង្គបុរេជំនុំជម្រះបានសម្រេចពីមុនរួចមកហើយថា ទាក់ទិននឹងយុត្តាធិការរបស់ខ្លួន អង្គបុរេជំនុំជម្រះ "នឹងធ្វើការពិនិត្យថាតើវិធាន២១ នៃវិធានផ្ទៃក្នុងតម្រូវឲ្យធ្វើការបកស្រាយសិទ្ធិរបស់ជនត្រូវចោទក្នុងការប្តឹងឧទ្ធរណ៍ ក្នុងន័យទូលាយឬទេ ដើម្បីធានាថា ដំណើរការនីតិវិធីក្នុងពេលស៊ើបសួរ មានភាពយុត្តិធម៌" សូមមើល សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់

៧. ចៅក្រមនៃអង្គបុរេជំនុំជម្រះបានសង្កត់ធ្ងន់រួចមកហើយ ពីសិទ្ធិទទួលបានព័ត៌មាន និងសិទ្ធិទទួលបានភាពយុត្តិធម៌ក្នុងកិច្ចដំណើរការនីតិវិធី សម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី/អ្នកដាក់ពាក្យសុំ[៨] ដែលជាភាគីនៅក្នុងកិច្ចដំណើរការនីតិវិធី។ ដោយសារស្ថានភាពធ្ងន់ធ្ងរនៃបញ្ហានេះ និងដោយមិនបានទទួលឧបាស្រ័យនោះ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីស្នើសុំថា អង្គបុរេជំនុំជម្រះគួរទទួលយកពាក្យបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការមិនឆ្លើយតប និងការមិនចាត់វិធានការរបស់ ស.ច.ស ដោយផ្អែកលើមូលដ្ឋាននៃវិធាន២១(១)(ក) និង (គ)។

## IV. សេចក្តីសន្និដ្ឋាន

៨. សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីកត់សម្គាល់ឃើញថា ភាពជាតំណាងតាមផ្លូវច្បាប់ជាកាតព្វកិច្ចចំពោះដើមបណ្តឹងរដ្ឋប្បវេណី។ ក៏ប៉ុន្តែ អ.វ.ត.ក មិនបានផ្តល់ការជួយផ្នែកច្បាប់ណាមួយដើម្បីធានាថា ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកដាក់ពាក្យសុំ មានតំណាងរបស់ខ្លួនតាមផ្លូវច្បាប់ទេ។ មានមេធាវីជាតិ ៣ នាក់ ដែលទទួលបានកិច្ចសន្យាការងារផ្នែកប្រឹក្សាយោបល់ជាមួយ អ.វ.ត.ក ដើម្បីតំណាងដើមបណ្តឹងរដ្ឋប្បវេណី។ កូនក្តីរបស់មេធាវីទាំងនោះមិនមានមេធាវីបរទេសតំណាងឡើយ ទោះបីជនរងគ្រោះបានលើក

---

លោក ខៀវ សំផន ប្រឆាំងនឹងដីកាសម្រេចស្តីពីសិទ្ធិ និងកាតព្វកិច្ចរបស់ភាគីទាក់ទងនឹងការបកប្រែ ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០៩ ឯកសារលេខ A190/I/20 កថាខណ្ឌ៣៦ និង សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេតសម្រេចបដិសេធសំណើសុំអនុញ្ញាតថតសំឡេង/រូបភាពវីដេអូ នៃការជួបជាមួយលោក អៀង សារី នៅក្នុងមន្ទីរឃុំឃាំង ឯកសារលេខ A371/2/12 កថាខណ្ឌ ១៣-១៤។

[៨] ដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីការួមរបស់សហចៅក្រមស៊ើបអង្កេត លេខ D250/3/3 ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១០ និង ដីកាលេខ D250/3/2 ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១០ ស្តីពី ភាពអាចទទួលបានសំណើសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី, ទស្សនៈរបស់ចៅក្រម ប្រាក់ គីមសាន និង ចៅក្រម Rowan Downing ស្តីពីការប្រកាសមិនទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលបានទទួលស្គាល់រួចហើយ ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១០ លេខ D250/3/1/5 កថាខណ្ឌ១៣ និង ដីកាសម្រេចមិនទទួលយកសំណើសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី D22/288, ទស្សនៈរបស់ចៅក្រម ប្រាក់ គីមសាន និង ចៅក្រម Rowan Downing ស្តីពីការប្រកាសមិនទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលបានទទួលស្គាល់រួចហើយ ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១០ លេខ D364 កថាខណ្ឌ១២។

ឡើងជាច្រើនលើកច្រើនសាថា ពួកគាត់មានអារម្មណ៍ទទួលបានការយកចិត្តទុកដាក់ស្មើគ្នា នឹងខាងភាគីចុងចោទច្រើនជាងមុន បើសិនពួកគាត់មានមេធាវីជាតិ និងអន្តរជាតិតំណាង ក៏ដោយ។

៩. មានដើមបណ្តឹងរដ្ឋប្បវេណី/អ្នកដាក់ពាក្យសុំប្រហែល ២/៣ មានតំណាងរបស់ខ្លួនជាមេធាវីជាតិ និងអន្តរជាតិដែលមិនបានទទួលការឧបត្ថមថវិកាពីសាលាក្តីនេះ ដែលមេធាវីទាំងនោះស្នើសុំឲ្យសាលាក្តីជួយសម្រាលបន្ទុក ដោយផ្តល់ភាពជាតំណាងតាមផ្លូវច្បាប់ (ជាកាតព្វកិច្ច)។ ដោយសារមូលហេតុនេះហើយទើបកម្រិតអប្បរមាដែលសាលាក្តីត្រូវផ្តល់ជាការគាំទ្រចាំបាច់សម្រាប់ភាគីទាំងអស់ផ្សេងទៀត គឺការប្រើប្រាស់អគាររបស់សាលាក្តី។

១០. ការមិនបង្កភាពងាយស្រួលឲ្យភាគីណាមួយបានប្រើប្រាស់អគាររបស់សាលាក្តី និងការដាក់ភាគីនោះនៅក្នុងមជ្ឈមណ្ឌលព័ត៌មានសាធារណៈ ជាសញ្ញាប្រកាសអាសន្នមួយរួចទៅហើយ។ ជាងនេះទៀត ភាគីមិនអាចធ្វើការងារបានពេញលេញពីខាងក្រៅសាលាក្តីបានទេ ដោយសារប្រព័ន្ធអេឡិកត្រូនិករបស់សាលាក្តីនេះ មិនបានផ្តល់ឲ្យបានការប្រើប្រាស់ពេញលេញពីចម្ងាយ ចំពោះបន្ទប់ឧបករណ៍អេឡិកត្រូនិកនានាដូចជា ឃ្លាំងផ្ទុកឯកសារ G និងឃ្លាំងផ្ទុកឯកសារ S ប្រព័ន្ធគ្រប់គ្រងសំណុំរឿង (case map) និងបណ្តុំឯកសារក្នុងប័ណ្ណសារ (archive folders)។ ដោយសារមូលហេតុនេះហើយទើបមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីត្រូវតែធ្វើការងារ នៅក្នុងបណ្តាញប្រព័ន្ធអេឡិកត្រូនិករបស់សាលាក្តី។

## V. ឧបត្ថម្ភករណ៍

## មូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍

***ស.ច.ស ភាន់ច្រឡំអង្គច្បាប់/វិធានផ្ទៃក្នុង នូវវិធាន២១ និង អង្គហេតុ ដោយប្រកាសថាសំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណីមិនស្ថិតក្នុងយុត្តាធិការរបស់ខ្លួន***

១១. សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានស្នើសុំឲ្យ ស.ច.ស រៀបចំលក្ខខណ្ឌធ្វើការងារឲ្យបានប្រហាក់ប្រហែលនឹងលក្ខខណ្ឌធ្វើការងារនៅសាលាក្តី ដោយការធានាឲ្យ

00616258



បានថា មិនមានការបើកចំហនូវឯកសារសម្ងាត់ (បំផុត) និងរៀបចំលក្ខខណ្ឌធ្វើការងារ សម្រាប់សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ឱ្យបានស្មើគ្នានឹងភាគីដទៃទៀតដែរ។ ស.ច.ស បដិសេធសំណើរបស់សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ដោយគ្រាន់តែសំអាងថា ខ្លួនមិនមានយុត្តាធិការទៅលើសំណើនេះទេ។

ការធ្វើបែបនេះ ស.ច.ស បានរំលោភវិធាន២១ និងវិធាន៣៥ នៃវិធានផ្ទៃក្នុង និងមានការភាន់ច្រឡំអង្គហេតុ។

១២. វិធាន២១ នៃវិធានផ្ទៃក្នុងបានកំណត់ថា "អ.វ.ត.ក" ត្រូវធានាដល់សិទ្ធិរបស់ជនរងគ្រោះ និងផ្ដល់ភាពយុត្តិធម៌។ ដោយសារវិធាននេះមិនបានបញ្ជាក់ច្បាស់លាស់ថាតើស្ថាប័នណាមួយនៃ អ.វ.ត.ក ត្រូវធានាសិទ្ធិជនរងគ្រោះ នោះគេអាចបកស្រាយតាមវិធីមួយដែលស្ថាប័នទាំងអស់នៃ អ.វ.ត.ក ត្រូវតែស្ថិតក្នុងបទដ្ឋាន និងការធានាទាំងនេះផងដែរ។ អង្គបុរេជំនុំជម្រះបានអនុវត្តយ៉ាងត្រឹមត្រូវនូវវិធីសាស្ត្រនេះ នៅក្នុងសេចក្ដីសម្រេចរបស់ខ្លួន៖ "ដោយហេតុថា នេះគឺជាបញ្ហាមួយពាក់ព័ន្ធនឹងគោលការណ៍ "ស្មើភាពគ្នាចំពោះមុខច្បាប់" និង "សមភាពនៃមធ្យោបាយតទល់រឿងក្ដី" **ដោយគិតពីភារកិច្ចរបស់អង្គជំនុំជម្រះ ដូចមានចែងត្រង់វិធាន២១ នៃវិធានផ្ទៃក្នុង ...**" (គូសបញ្ជាក់បន្ថែម)។

១៣. បន្ទាប់ពីប្រធាន និងអនុប្រធានការិយាល័យរដ្ឋបាលបានទទួលការជូនដំណឹងពីបញ្ហាទាំងអស់នេះជាច្រើនដងមកហើយ តែមិនមានការផ្លាស់ប្ដូរជាដុំកំភួន ទើបសហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីលើកបញ្ហាទាំងនេះទៅ ស.ច.ស ដោយសារ ស.ច.ស មានសកម្មភាពពាក់ព័ន្ធ ក្នុងដំណាក់កាលមុនសវនាការនេះ ដើម្បីដោះស្រាយសំណើ និងស្របតាមភារកិច្ចរបស់ខ្លួនដែលមានចែងក្នុងវិធាន២១ នៃវិធានផ្ទៃក្នុងផង ប្រសិនបើការិយាល័យរដ្ឋបាលខកខានមិនបានអនុវត្តតាមវិធានផ្ទៃក្នុង ទាក់ទិននឹងទិដ្ឋភាពនេះ។

## ក. ការរក្សាការសម្ងាត់

១៤. ស.ច.ស ដែលមានភារកិច្ចធ្ងន់ធ្ងរជាងគេ ជាអ្នករក្សាការសម្ងាត់ក្នុងដំណើរការកិច្ចស៊ើបសួរ អនុលោមតាមវិធាន៥៦(១) នៃវិធានផ្ទៃក្នុង មានភារកិច្ចចាត់វិធានការនានាដែលចាំបាច់និងសមស្រប ដើម្បីការពារដំណើរការកិច្ចស៊ើបសួរមិនឱ្យបែកធ្លាយ ដែលអាចកើត

00616259



ឡើងដោយសារលក្ខខណ្ឌធ្វើការងារ របស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ហើយធានាថាសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីអាចរក្សាបាននូវភារកិច្ចវិជ្ជាជីវៈរបស់ខ្លួន ចំពោះការរក្សាការសម្ងាត់។

១៥. មេធាវីទាំងអស់ដែលបំពេញការងារនៅ អ.វ.ត.ក រួមទាំងមេធាវីអន្តរជាតិផង ត្រូវបានចុះបញ្ជីនៅគណៈមេធាវីកម្ពុជា (វិធាន១១(២)(ខ) វិធាន៣៩ និងវិធាន២២(១)(ក) នៃវិធានផ្ទៃក្នុង) ហើយត្រូវតែគោរពតាមក្រមសីលធម៌វិជ្ជាជីវៈមេធាវី។ មាត្រា៧ នៃក្រមសីលធម៌វិជ្ជាជីវៈមេធាវីចែងថា៖ "មេធាវីត្រូវប្រកាន់ឱ្យបានខ្ជាប់ខ្ជួនដាច់ខាត នូវអាថ៌កំបាំងវិជ្ជាជីវៈ។ អាថ៌កំបាំងនេះមិនត្រូវឱ្យជនណាស្រង់យកបានឡើយ ទោះបីជាអតិថិជនក៏ដោយ"[៩]។

១៦. ទាក់ទិននឹងការសម្ងាត់ ក.ស.ច.ស មានភារកិច្ចដាច់ខាតក្នុងការធ្វើសកម្មភាពភ្លាម ដើម្បីការពារការសម្ងាត់នៃកិច្ចស៊ើបសួរផង ក៏ដូចជាអនុវត្តឱ្យមេធាវីអនុវត្តតាមក្រមសីលធម៌របស់គណៈមេធាវីផង។ ជាងនេះទៅទៀត បន្ទាប់ពីបានទទួលដំណឹងស្តីពីបញ្ហានេះហើយ ស.ច.ស ត្រូវផ្តួចផ្តើមចាត់វិធានការ ពិនិត្យមើលថាតើ "មានហេតុផលជឿថា បុគ្គលណាម្នាក់អាចធ្លាប់បានប្រព្រឹត្តិអំពើណាមួយ ដូចចែងក្នុងអនុវិធាន៣៥(១)"[១០]។ ដោយហេតុថា ការិយាល័យរដ្ឋបាលមិនបានយកចិត្តទុកដាក់ចំពោះបញ្ហាទាំងនេះ នៅពេលបញ្ហាទាំងនេះត្រូវបានបញ្ជូនមកការិយាល័យ និងដោយសារការិយាល័យនេះមិនអនុវត្តតាមវិធាន២១ នេះជាកាតព្វកិច្ចផ្ទាល់របស់ ស.ច.ស ក្នុងការចាត់វិធានការយ៉ាងសមរម្យក្នុងការដោះស្រាយបញ្ហាទាំងនេះ ដើម្បីចៀសវាងការចូលជ្រៀតជ្រែកណាមួយទៅក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ។

## ខ. លក្ខខណ្ឌធ្វើការងារ

១៧. សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក៏បានស្នើផងដែរទៅ ក.ស.ច.ស សុំឱ្យរៀបចំលក្ខខណ្ឌធ្វើការងារដូចពីមុន ជាពិសេសទាក់ទិននឹងដំណើរការយឺតយ៉ាវនៃប្រព័ន្ធ zylab

[៩] ក្រមសីលធម៌មេធាវីដែលបានចុះបញ្ជីនៅគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា នៅគេហទំព័រ http://www.bigpond.com.kh/council_of_jurists/judicial/jud002g.htm។

[១០] វិធាន៣៥(២) នៃផ្ទៃក្នុង។

00616260



ការកំណត់រយៈឱ្យដាក់ឯកសារខ្លីជាងមុន និងបញ្ហាកង្វះទីកន្លែងនិងសម្ភារៈសម្រាប់ធ្វើការងារ។ ក្នុងការច្រានចោលសំណើនេះ ដោយសំអាងថា ស.ច.ស មិនមានយុត្តាធិការនោះ ស.ច.ស ខកខានមិនបានអនុវត្តតាមវិធាន២១ គោលការណ៍មូលដ្ឋានរបស់អង្គការសហប្រជាជាតិស្តីពីជនរងគ្រោះ និង ICCPR។ ជាងនេះទៅទៀត ស.ច.ស ភាន់ច្រឡំលើអង្គហេតុ។

១៨. អនុលោមតាមវិធានផ្ទៃក្នុង ដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិក្នុងការចូលរួម និងសិទ្ធិទទួលបានសំណង។ ដើម្បីឱ្យគេអាចអនុវត្តនូវសិទ្ធិទាំងនេះបាន មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីត្រូវមានលក្ខខណ្ឌធ្វើការងារ ដែលអនុញ្ញាតឱ្យពួកគេអាចបំពេញការងារបាន។ ប្រសិនបើលក្ខខណ្ឌធ្វើការងារទាំងនេះមិនត្រូវបានផ្តល់ឱ្យនោះទេ ការអនុវត្តសិទ្ធិទាំងនេះក៏មិនអាចធ្វើទៅបានដែរ ឬយ៉ាងហោចណាស់ក៏មិនអាចអនុវត្តសិទ្ធិនេះបានដែរ។

១៩. គោលការណ៍មូលដ្ឋានរបស់អង្គការសហប្រជាជាតិ ដែលបង្កើតឡើងសម្រាប់ជនរងគ្រោះពីការបំពានធ្ងន់ធ្ងរលើច្បាប់សិទ្ធិមនុស្សអន្តរជាតិ ក្នុងការទទួលបានយុត្តិធម៌ ក្នុងកិច្ចដំណើរការនីតិវិធីយ៉ាងត្រឹមត្រូវ និងតម្រូវឱ្យ "ចាត់វិធានការកាត់បន្ថយការលំបាករបស់ជនរងគ្រោះ និងតំណាងរបស់ពួកគាត់" "ដើម្បីផ្តល់ជំនួយយ៉ាងសមរម្យដល់ជនរងគ្រោះដែលស្វែងរកយុត្តិធម៌" និង "ដើម្បីផ្តល់តាមផ្លូវច្បាប់សមរម្យ ... នូវមធ្យោបាយដើម្បីធានាថាជនរងគ្រោះអាចអនុវត្តសិទ្ធិរបស់ខ្លួនបាន..."[១១]។

២០. មាត្រា១៤(១) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ធានាថាសិទ្ធិទទួលបានការសម្រេចប្រកបដោយយុត្តិធម៌ចំពោះបញ្ហាណាមួយ និងការប្រើប្រាស់តុលាការមួយគឺជាបុរេលក្ខខណ្ឌ។ មាត្រានេះក៏ធានាឱ្យមានការបញ្ជាក់ឱ្យបានច្បាស់ថាតើបញ្ហានោះគឺជាបញ្ហាបណ្តឹងព្រហ្មទណ្ឌ ឬបណ្តឹងរដ្ឋប្បវេណី ឬជាបណ្តឹងរដ្ឋប្បវេណីនៅក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌ។ មាត្រា១៤(១) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដែលចែងថា៖

> "ជនគ្រប់រូប ត្រូវមានភាពស្មើគ្នាចំពោះមុខតុលាការ និងសាលាជម្រះក្តី។ ជនគ្រប់រូបត្រូវមានសិទ្ធិឱ្យសាលាក្តីមានសមត្ថកិច្ចឯករាជ្យ និងមិនលំអៀង ដែល

[១១] មើលទំព័រលេខ៥ កថាខណ្ឌ១២ និង ១២(ខ), ១២(គ), ១២(ឃ)។

បង្កើតឡើងដោយច្បាប់ជំនុំជម្រះរឿងក្តីរបស់ខ្លួន ដោយសមធម៌ និងជាសាធារណៈ ដើម្បីសម្រេចលើការចោទប្រកាន់ប្រឆាំងមកលើខ្លួនក្នុងវិស័យព្រហ្មទណ្ឌ ឬលើសិទ្ធិ និងករណីកិច្ចក្នុងវិស័យរដ្ឋប្បវេណី"។

២១. ប្រសិនបើការប្រើប្រាស់តុលាការមិនបានពេញលេញ និងប្រសិនបើលក្ខខណ្ឌធ្វើការងាររបស់មេធាវីដែលតំណាងដើមបណ្តឹងរដ្ឋប្បវេណី មានលក្ខណៈទន់ទាបជាងភាគីផ្សេងទៀតនោះ ការធានាក្នុងការទទួលបាននំណើរការនីតិវិធីប្រកបដោយយុត្តិធម៌ ដែលមានចែងក្នុងមាត្រា១៤(១) នៃ ICCPR នោះ មិនត្រូវបានគេផ្តល់ឱ្យឡើយ។

២២. អាស្រ័យហេតុនេះ ដោយសារការិយាល័យរដ្ឋបាលបដិសេធមិនរៀបចំលក្ខខណ្ឌធ្វើការងារឱ្យបានស្មើភាពនោះ ស.ច.ស ក្លាយជាស្ថាប័នមានសមត្ថកិច្ចតែមួយគត់ក្នុងដំណាក់មុនពេលសវនាការដែលមានកាតព្វកិច្ច ចាត់វិធានការចាំបាច់ និងសមរម្យ។ ដោយការច្រានចោលសំណើនេះ ស.ច.ស បានរំលោភលើសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការទទួលបាននូវការជំនុំជម្រះប្រកបដោយយុត្តិធម៌ ដូចដែលបានចែងក្នុងមាត្រា១៤(១) នៃ ICCPR វិធាន២១ និងគោលការណ៍មូលដ្ឋានរបស់អង្គការសហប្រជាជាតិ។ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីស្នើថា ស.ច.ស បានសម្រេចដោយភាន់ច្រឡំថា សំណើនេះមិនស្ថិតក្រោមយុត្តាធិការរបស់ខ្លួនទេ។

២៣. សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីកត់សម្គាល់ថា អ.ប.ជ បានសង្កេតឃើញថា "ស.ច.ស ខកខានមិនបានបំពេញភារកិច្ចរបស់ខ្លួនម្តងហើយម្តងទៀត"[១២]។

៨១. អាស្រ័យហេតុនេះ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីសូមលើកសំណើជូនអង្គបុរេជំនុំជម្រះមេត្តា៖

(i) ប្រកាសថាបណ្តឹងឧទ្ធរណ៍នេះទទួលយកបាន។

---

[១២] សាលដីកាលើកទីពីរលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី និង លោក នួន ជា ប្រឆាំងនឹងដីកាសម្រេចរបស់ ក.ស.ច.ស ថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០១០ មតិយោបល់របស់ចៅក្រម Catherine Marhul-Uhel និង ចៅក្រម Rowan Downing កថាខណ្ឌ៥។

(ii) សម្រេចទៅលើសំណើរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ ដោយចាត់វិធានការចាំបាច់ ដើម្បីរៀបចំលក្ខខណ្ឌធ្វើការងាររបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីឲ្យបានប្រហាក់ប្រហែលនឹងលក្ខខណ្ឌធ្វើការងារនៅតុលាការនេះ ដោយត្រូវធានាមិនឲ្យបញ្ចេញឯកសារសម្ងាត់ (បំផុត) និងរៀបចំលក្ខខណ្ឌធ្វើការងារឲ្យបានស្មើគ្នានឹងលក្ខខណ្ឌធ្វើការងាររបស់ភាគីដទៃទៀត។

| | |
|---|---|
| លោក ហុង គឹមសួន | លោកស្រី ស៊ិន សុវ៉ន |
| លោក គង់ ពិសី | លោក យ៉ុង ផានិត |
| លោកស្រី Lyma NGUYEN | អ្នកស្រី Silke STUDZINSKY |

ចុះហត្ថលេខានៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា នៅថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១០